# សេចក្តីប្រកាសរួម
# ត្រូវតែបញ្ឈប់វប្បធម៌និទណ្ឌភាព និង អំពើហិង្សា

**រាជធានីភ្នំពេញ ថ្ងៃទី 30 ខែ ឧសភា ឆ្នាំ ២០១២** — យើងខ្ញុំជាអង្គការសង្គមស៊ីវិល ជាតិ និង អន្តរជាតិ ដែលមានឈ្មោះនៅក្នុងសេចក្តីថ្លែងការណ៍នេះ សូមថ្កោលទោសចំពោះការប្រើកម្លាំងប្រដាប់អាវុធ និង ការកើនឡើងនូវអំពើហិង្សា ប្រឆាំងនឹងប្រជាពលរដ្ឋដែលទាមទារ ការការពារសិទ្ធិរបស់ពួកគាត់ លើសិទ្ធិដីធ្លី សិទ្ធិធនធានធម្មជាតិ និង សិទ្ធិការងារ ។ យើងខ្ញុំទាំងអស់គ្នាមិនមែនសំដៅតែទៅលើព្រឹត្តិការណ៍បានកើតឡើង នៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២ ដែលអ្នកតវ៉ាដោយសន្តិវិធីរាប់សិបនាក់ ជាប្រជាជននៅតំបន់បឹងកក់ត្រូវបានបង្ក្រាបដោយហិង្សា និងពីរថ្ងៃក្រោយមក តំណាងប្រជាពលរដ្ឋបឹងកក់ចំនួន ១៥ នាក់ (ស្រី ១៤ នាក់ និង ប្រុស ១ នាក់) ត្រូវបានចាប់ខ្លួនបញ្ជូនទៅតុលាការ និង កាត់ទោសដាក់ ពន្ធនាគារព្រៃសរ ដោយគ្មានភស្តុតាងគ្រប់គ្រាន់ប៉ុ ណ្ណោះទេ[1] ប៉ុន្តែឧប្បត្តិហេតុបាញ់សំលាប់ថ្មីៗ ដូចជាការសម្លាប់លោក ឈុត វុទ្ធី សកម្មជនបរិស្ថាន[2] នៅខេត្តកោះកុង ការបាញ់សំលាប់កុមារី ហេង ចាន់ថា[3] អាយុ ១៤ ឆ្នាំ នៅខេត្តក្រចេះ និងការបាញ់ប្រហារលើស្ត្រីបីរូប ដែលទាមទារលក្ខខណ្ឌការងារល្អប្រសើរនៅខេត្តស្វាយរៀង ។ ឧប្បត្តិហេតុទាំងអស់នេះ គឺគួរឲ្យព្រួយបារម្ភយ៉ាងខ្លាំង ព្រោះវាបង្ហាញនូវការកើនឡើង នៃការត្រៀមជាមុននូវកងកម្លាំងសន្តិសុខនិងយោធាក្នុងការប្រើកម្លាំងប្រឆាំងនឹងជនស៊ីវិលរហូតដល់បាត់បង់ជីវិត ។

ក្នុងឆ្នាំ ២០១២ យ៉ាងហោចណាស់ មានករណីបែបនេះចំនួន ប្រាំ បានកើតឡើង ដោយមិនបានរាប់បញ្ចូលករណីរំលោភសិទ្ធិមនុស្សផ្សេងៗទៀតឡើយ ។ យើងខ្ញុំមានកង្វល់ រន្ធត់ និង ក្រៀមក្រំយ៉ាងខ្លាំង អំពីកំណើននៃអំពើហិង្សានេះ ជាពិសេសវិវាទទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច ។ មាត្រា ៤១ នៃ រដ្ឋធម្មនុញ្ញកម្ពុជា និង អនុសញ្ញាអន្តរជាតិនានាដែលប្រទេសកម្ពុជា ជាភាគីហត្ថលេខី បញ្ជាក់ថា ប្រជាពលរដ្ឋមានសិទ្ធិជាមូលដ្ឋានក្នុងការសម្តែងមតិដោយសេរី ដែលរួមមានសិទ្ធិតវ៉ាទាមទារនឹងសេចក្តីសម្រេចរបស់អាជ្ញាធរសាធារណៈ ដែលរំលោភលើសិទ្ធិនិងជីវភាពរបស់ពួកគេ ។ ក្នុងការអនុវត្តជាក់ស្តែង ការអនុវត្តសិទ្ធិនេះ មិនត្រូវបានគោរព ឬ ទទួលរងការបង្ក្រាបដោយហិង្សា។

---

[1] The Phnom Penh Post, Friday, 25. May 2012 Page 1, 2; The Phnom Penh Post, Monday 28. May 2012 Page 1,
[2] The Phnom Penh Post, Friday 27.April 2012, Page 1, 2
[3] The Cambodian Daily, Thursday 17. May 2012

---

ព័ត៌មានបន្ថែមអំពី អង្គការដែលបានចុះហត្ថលេខាគាំទ្រសេចក្តីថ្លែងការណ៍រួមនេះ សូមទាក់ទងជាមួយ:
១- វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF) ផ្ទះលេខ: ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៤ ៤២៩ ទូរសារលេខ: (៨៥៥) ២៣ ៩៩៤ ០៦៣ អ៊ីម៉ែល: info@ngoforum.org គេហទំព័រ: www.ngoforum.org.kh
២- គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ផ្ទះលេខ: ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៤ ១៥២ ទូរសារលេខ: (៨៥៥) ២៣ ២១៦ ០០៩ អ៊ីម៉ែល: info@ccc-cambodia.org គេហទំព័រ: www.ccc-cambodia.org
៣- គណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ផ្ទះលេខ: ៩E0 ផ្លូវលេខ: ៣៣០ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ៣០១ ៤១៥ ទូរសារលេខ: (៨៥៥) ២៣ ២១៨ ៧៥៩ អ៊ីម៉ែល: chrac@forum.org.kh គេហទំព័រ: www.chrac.org

ប្រជាជនកម្ពុជាមានសិទ្ធិរស់នៅក្រោមនីតិរដ្ឋ ។ ពួកគាត់ត្រូវទទួលបានកិច្ចការពារ និងសេវាកម្មប្រកបដោយសេចក្តីថ្លៃថ្នូរនិងយុត្តិធម៌ ដោយផ្អែកលើសិទ្ធិជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល ។ អាជ្ញាធរសាធារណៈមិនមែនមានតែកាតព្វកិច្ចនិងករណីយកិច្ចក្នុងការធានាឲ្យបានថា វប្បធម៌និទណ្ឌភាពមិនត្រូវបានលើកលែងប៉ុណ្ណោះទេ ប៉ុន្តែការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាពត្រូវចាត់ទុកជាកិច្ចការអាទិភាពមួយរបស់អាជ្ញាធរសាធារណៈ ។ គ្រប់ករណីទាំងអស់ដែលទាក់ទងនឹងការប្រើអាវុធប្រឆាំងនឹងជនស៊ីវិល គប្បីត្រូវស៊ើបអង្កេតជាបន្ទាន់ ដោយលំអិត និង ដោយឥតលំអៀង ។ ការស៊ើបអង្កេត ដែលបានរកឃើញថាការបាញ់ប្រហារទាំងឡាយគឺ "ដោយចៃដន្យ" ឬ ថាដោយសារមន្ត្រីថ្នាក់ទាបបានធ្វើសកម្មភាពតាមទំនើងចិត្តរបស់ខ្លួន គប្បីត្រូវបានគាំទ្រដោយភស្តុតាងដែលបានប្រមូលក្នុងលក្ខណៈម៉ឺងម៉ាត់និងតម្លាភាព ។ ដោយឡែកសាក្សីគួរគប្បីត្រូវបានការពារពីការគម្រាមកំហែងនិងការបំភិតបំភ័យ ហើយជនរងគ្រោះទាំងអស់ គប្បីទទួលបានការដោះស្រាយតាមផ្លូវតុលាការប្រកបដោយប្រសិទ្ធភាព និង យុត្តិធម៌។

ទោះបីជាសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាស មិនឲ្យប្រើប្រាស់អាវុធប្រឆាំងនឹងអ្នកតវ៉ា[4] និង បានចេញបទបញ្ជាប្រកាសឱសានវាទលើការផ្តល់សម្បទានដីសេដ្ឋកិច្ចក្តី[5] ថ្មីៗនេះ ករណីបាញ់ប្រហារនៅតែមានកើតឡើង។ អង្គការសង្គមស៊ីវិល សូមស្វាគមន៍ចំពោះបទបញ្ជារបស់សម្តេចនាយករដ្ឋមន្ត្រី ដែលសំដៅលើកស្ទួយស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ។ ជាពិសេស បទបញ្ជានេះ គប្បីត្រូវមានគោលការណ៍ណែនាំលម្អិតនិងកំណត់អំពីរបៀបដែលអាជ្ញាធរសាធារណៈ រួមមានអាជ្ញាធរថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្ត និង កងកម្លាំងប្រដាប់អាវុធទាំងអស់ ត្រូវអនុវត្តឲ្យបានម៉ឺងម៉ាត់និងជាប្រព័ន្ធ។

ការពិនិត្យមើលឡើងវិញលើក្រុមហ៊ុនទទួលបានសម្បទានដែលកំពុងវិនិយោគនៅកម្ពុជា គឺមានសារៈសំខាន់ណាស់ ដើម្បីធានាថា ក្រុមហ៊ុនទាំងនោះគោរពទៅតាមក្របខណ្ឌគតិយុត្តិជាតិនិងអន្តរជាតិ ។ ការខ្វះខាតធនធាន ឬ សមត្ថភាពបច្ចេកទេសនានា គប្បីត្រូវកំណត់និងដោះស្រាយ ហើយការអនុវត្តសេចក្តីសំរេចទាំងនេះ គប្បីត្រូវបានតាមដាននិងរាយការណ៍ជូនសាធារណជន។

---

[4] The Cambodian Daily, Wednesday, 1st of February 2012, Page 1, 2

[5] Royal Government of Cambodia, No.01 BB, 07th of May, Directive on Measures to Strengthen and Enhance the Effectiveness of the Economic Land Concession Management

---

ព័ត៌មានបន្ថែមអំពី អង្គការដែលបានចុះហត្ថលេខាគាំទ្រសេចក្តីថ្លែងការណ៍រួមនេះ សូមទាក់ទងជាមួយ:
១- វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF) ផ្ទះលេខ: ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៤ ៤២៩ ទូរសារលេខ: (៨៥៥) ២៣ ៩៩៤ ០៦៣ អ៊ីម៉ែល: info@ngoforum.org គេហទំព័រ: www.ngoforum.org.kh
២- គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ផ្ទះលេខ: ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៤ ១៥២ ទូរសារលេខ: (៨៥៥) ២៣ ២១៦ ០០៩ អ៊ីម៉ែល: info@ccc-cambodia.org គេហទំព័រ: www.ccc-cambodia.org
៣- គណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ផ្ទះលេខ: ៩E0 ផ្លូវលេខ: ៣៣០ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ៣០១ ៩១៥ ទូរសារលេខ: (៨៥៥) ២៣ ២១៨ ៧៥៩ អ៊ីម៉ែល: chrac@forum.org.kh គេហទំព័រ: www.chrac.org

យើងខ្ញុំជា អង្គការសង្គមស៊ីវិលចំនួន ១២១ ដែលបានចុះហត្ថលេខាគាំទ្រសេចក្តីថ្លែងការណ៍នេះ ជឿជាក់ថា អំពើហិង្សាប្រឆាំងនឹងជនស៊ីវិល ជាទង្វើមិនអាចទទួលយកបានគ្រប់កាលៈទេសៈ និង គប្បីបញ្ឈប់ជាបន្ទាន់ ហើយយើងខ្ញុំនឹងតាមដានករណីនីមួយៗទាក់ទងនឹងសិទ្ធិដីធ្លី សិទ្ធិធនធានធម្មជាតិ និង សិទ្ធិការងារបន្តទៀត ។ ម្យ៉ាងទៀត យើងខ្ញុំនឹងបន្តស្វែងរកកិច្ចសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលដៅពង្រឹងនីតិរដ្ឋ និង លុបបំបាត់វដ្តនៃអំពើហិង្សានិងនិទណ្ឌភាព។

សេចក្តីប្រកាសនេះ ត្រូវបានគាំទ្រដោយអង្គការសង្គមស៊ីវិល ជាតិ និងអន្តរជាតិដូចមានរាយនាមខាងក្រោម:

1) 3S Rivers Protection Network (3SPN)
2) Action for Environment and Communities (AEC)
3) Action for Research and Development (ARD)
4) ActionAid International-Cambodia
5) Advocacy and Policy Institute (API)
6) Affiliated Network for Social Accountability-East Asia and the Pacific (ANSA-EAP CAMBODIA)
7) Aide Et Action International-Cambodia
8) Alliance Action for Rural Restoration Organization (AARR)
9) Asian Human Rights Commission (AHRC)
10) Assistance to Poor Children's Agency (APCA)
11) Australian Council for International Development (ACFID)
12) Banteay Srei (BS)
13) Buddhism for Development (BFD)
14) Building Communities Voices (BCV)
15) Burma Partnership
16) Cambodia Women's Crisis Center (CWCC)
17) Cambodia's Media Forum on Environment (CMFE)
18) Cambodian Center for Independent Media (CCIM)
19) Cambodian Centre for Human Rights (CCHR)
20) Cambodian Children's Trust (CCT)
21) Cambodian Civil Society Partnership (CCSP)
22) Cambodian Defenders Project (CDP)
23) Cambodian Food and Service Workers Federation (CFSWF)
24) Cambodian HIV/AIDS Education and Care (CHEC)
25) Cambodian Human Rights Action Committee (CHRAC)
26) Cambodian Human Rights and Development (ADHOC)
27) Cambodian Indigenous Youth Association (CIYA)
28) Cambodian League for the Promotion and Defense of Human Rights (LICADHO)
29) Cambodian Mental Health Nurses Association (CMHNA)
30) Cambodian National Research Organization (CNRO)
31) Cambodian Rural Development Team (CRDT)
32) Cambodian Volunteers for Society (CVS)
33) Cambodian Worker Center for Development (DWCD)
34) Cambodian Center for the Protection of Children's Rights (CCPCR)
35) Center for Advanced Study (CAS)

---

ព័ត៌មានបន្ថែមអំពី អង្គការដែលបានចុះហត្ថលេខាគាំទ្រសេចក្តីថ្លែងការណ៍រួមនេះ សូមទាក់ទងជាមួយ:

១- វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF) ផ្ទះលេខ: ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៤ ៤២៩ ទូរសារលេខ: (៨៥៥) ២៣ ៩៩៤ ០៦៣ អ៊ីម៉ែល: info@ngoforum.org គេហទំព័រ: www.ngoforum.org.kh

២- គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ផ្ទះលេខ: ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៤ ១៥២ ទូរសារលេខ: (៨៥៥) ២៣ ២១៦ ០០៩ អ៊ីម៉ែល: info@ccc-cambodia.org គេហទំព័រ: www.ccc-cambodia.org

៣- គណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ផ្ទះលេខ: ៩E0 ផ្លូវលេខ: ៣៣០ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ៣០១ ៤១៥ ទូរសារលេខ: (៨៥៥) ២៣ ២១៨ ៧៥៩ អ៊ីម៉ែល: chrac@forum.org.kh គេហទំព័រ: www.chrac.org

36) Child Hope Cambodia
37) Children and Life Association (CLA)
38) Children Development Association (CDA)
39) Christian Reformed World Relief Committee (CRWRC)
40) Christians for Social Justice (CSJ)
41) Coalition for Integrity and Social Accountability (CISA)
42) Coalition of Cambodian Farmer Community (CCFC)
43) Community Capacities for Development (CCD)
44) Community Economic Development (CED)
45) Community Empowerment and Development Team (CEDT)
46) Community Managed Development Partners (CMDP)
47) Community Peace-Building Network (CPN)
48) Concern Worldwide Cambodia
49) Cooperation Committee for Cambodia (CCC)
50) CORD South & East Asia
51) Culture and Environment Preservation Association (CEPA)
52) DanChurchAid/ChristianAid
53) Danmission-Cambodia
54) Development and Partnership in Action (DPA)
55) Development and Peace-Canada
56) Diakonia
57) Elephant Livelihood Initiative Environment (ELIE)
58) Environment and Society Organization ( ESO)
59) Environmental Protection and Development Organization(EPDO)
60) Equitable Cambodia
61) Farmer of Cambodia Organization (FOC)
62) Forum Syd
63) Friends of the Earth Indonesia (WALHI)-based in Indonesia
64) Gender and Development for Cambodia (GADC)
65) Heinrich Böll Stitfung Cambodia
66) Highlander Association (HA)
67) Housing Rights Task Force (HRTF)
68) ICCO & KiA Southeast Asia and Pacific
69) Inclusive Development International
70) Independent Democracy of Informal Economic Association (IDEA)
71) Indigenous Community Support Organization (ICSO)
72) Indigenous Rights Active Members (IRAM)
73) International Center for Conciliation (ICfC)
74) Japan International Volunteer Center (JVC)
75) Jesuit Service Cambodia
76) Kelompok Studi Konservasi (KSK)- based in Indonesia
77) Khmer Institute for National Development (KIND)
78) Khmer Youth Association (KYA)
79) Korean Missionary Society (KMS)
80) Krom Akphiwat Phum (KAWP)
81) Kunathor (TNK)
82) LICADHO Canada
83) Life with Dignity (LWD)
84) Mercy Teams International
85) Mlup Baitong (MB)

---

ព័ត៌មានបន្ថែមអំពី អង្គការដែលបានចុះហត្ថលេខាគាំទ្រសេចក្តីថ្លែងការណ៍រួមនេះ សូមទាក់ទងជាមួយ:

១- វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF) ផ្ទះលេខ: ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៤ ៤២៩ ទូរសារលេខ: (៨៥៥) ២៣ ៩៩៤ ០៦៣ អ៊ីម៉ែល: info@ngoforum.org គេហទំព័រ: www.ngoforum.org.kh

២- គណ:កម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ផ្ទះលេខ: ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៤ ១៥២ ទូរសារលេខ: (៨៥៥) ២៣ ២១៦ ០០៩ អ៊ីម៉ែល: info@ccc-cambodia.org គេហទំព័រ: www.ccc-cambodia.org

៣- គណ:កម្មាធិការប្រព្រឹត្តកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ផ្ទះលេខ: ៩E0 ផ្លូវលេខ: ៣៣០ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ៣០១ ៤១៥ ទូរសារលេខ: (៨៥៥) ២៣ ២១៨ ៧៥៩ អ៊ីម៉ែល: chrac@forum.org.kh គេហទំព័រ: www.chrac.org

86) My Village (MVi)
87) Neak Poan Organization For Development (NOP)
88) Neutral and Impartial Committee for Free and Fair Elections in Cambodia (NICFIC)
89) NGO Committee on the Rights of the Child (NGOCRC)
90) NGO Education Partnership (NEP)
91) NGO Forum on Cambodia (NGOF)
92) Non-Timber Forest Products (NTFP)
93) Norwegian People’s Aid (NPA)-Cambodia
94) Operations Enfants du Cambodge (OEC)
95) Organization to Promote Kuy Culture (OPKC)
96) Partnership for Development in Cambodia (PADEK)
97) People in Need Cambodia (PIN-Cambodia)
98) People’s Action for Change (PAC)
99) Phum Baitong
100) Ponleu Ney Kdey SangKhum (PNKS)
101) Ponlok Khmer (PKH) based in Preah Vihear
102) RACHANA
103) Reproductive Health Association of Cambodia (RHAC)
104) Riverkids Foundation
105) Sahmakum Teang Tnaut (STT)
106) Save the Children
107) Servants of Cambodia
108) Shelter for the Poor
109) Silaka
110) Social Action for Change (SAC)
111) STAR Kampuchea
112) Strey Khmer Organization (SKO)
113) The Cambodian Center for the Protection of the Children’s Rights (CCPCR)
114) Trócaire
115) Urban Poor Development Fund (UPWD)
116) Village Focus Cambodia (VFC)
117) Volunteers for Sustainable Development (VSD)
118) Welthungerhilfe Cambodia (DWHH/GAA)
119) Women Association for Community Development (WACD)
120) World Rainforest Movement (WRM)
121) World Vision Cambodia (WVC)
122) Youth Resource Development Programme (YRDP)

---

ព័ត៌មានបន្ថែមអំពី អង្គការដែលបានចុះហត្ថលេខាគាំទ្រសេចក្តីថ្លែងការណ៍រួមនេះ សូមទាក់ទងជាមួយ:
១- វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF) ផ្ទះលេខ: ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៤ ៤២៩ ទូរសារលេខ: (៨៥៥) ២៣ ៩៩៤ ០៦៣ អ៊ីម៉ែល: info@ngoforum.org គេហទំព័រ: www.ngoforum.org.kh
២- គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ផ្ទះលេខ: ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៤ ១៥២ ទូរសារលេខ: (៨៥៥) ២៣ ២១៦ ០០៩ អ៊ីម៉ែល: info@ccc-cambodia.org គេហទំព័រ: www.ccc-cambodia.org
៣- គណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ផ្ទះលេខ: ៩E0 ផ្លូវលេខ: ៣៣០ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទលេខ: (៨៥៥) ២៣ ៣០១ ៥១៥ ទូរសារលេខ: (៨៥៥) ២៣ ២១៨ ៧៥៩ អ៊ីម៉ែល: chrac@forum.org.kh គេហទំព័រ: www.chrac.org